Garment Manufacturers Association in Cambodia

# សេចក្ដីជូនដំណឹងដល់រោងចក្រផលិតផលធ្វើដំណើរទាំងអស់ក្នុងប្រទេសកម្ពុជា

**កម្មវត្ថុ៖ ការផុតរលត់នៃកម្មវិធីអនុគ្រោះពន្ធទូទៅរបស់សហរដ្ឋអាមេរិក(US GSP)**

សមាគមសូមជម្រាបសមាជិកទាំងអស់ថា កម្មវិធីអនុគ្រោះពន្ធទូទៅរបស់សហរដ្ឋអាមេរិកបានផុតរលត់សុពលភាពកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដោយសារការយឺតយ៉ាវក្នុងការអនុម័តច្បាប់ដើម្បីផ្ដល់សុពលភាពដល់កម្មវិធីនេះឡើងវិញដោយសភាអាមេរិក។ ការយឺតយ៉ាវនេះជាបញ្ហាពាក់ព័ន្ធមួយដល់ប្រទេសនិងដែនដីចំនួន១១៩ដែលទទួលបានផលពីកម្មវិធីនេះ (កម្ពុជា ជាប្រទេសមួយក្នុងចំណោមនោះដែរ) ប៉ុន្តែផលប៉ះពាល់ផ្ទាល់នឹងមានទៅលើអ្នកបញ្ជាទិញ/អ្នកនាំចូលដែលនឹងត្រូវតម្រូវឲ្យបង់ពន្ធនាំចូលរហូតដល់កម្មវិធីនេះត្រូវបានផ្ដល់សុពលភាពឡើងវិញ។

ដោយចាប់ផ្ដើមពីឆ្នាំ១៩៧៤ កម្មវិធីអនុគ្រោះពន្ធទូទៅរបស់សហរដ្ឋអាមេរិកត្រូវបានផ្ដល់ឲ្យដំបូងរយៈពេល១០ឆ្នាំ។ ចាប់តាំងពីពេលនោះមក កម្មវិធីនេះត្រូវបានផ្ដល់សុពលភាពឲ្យអនុវត្តជាបន្តបន្ទាប់ចំនួន១៤ដង ដែលជាទូទៅការផ្ដល់ទាំងនោះមានសុពលភាពរយៈពេលពី២ទៅ៣ឆ្នាំ។ ក្នុងអំឡុងរយៈពេលនៃការផុតរលត់ចុងក្រោយនេះ ទំនិញដែលនាំចូលទៅក្នុងសហរដ្ឋអាមេរិកបន្ទាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ នឹងជាប់អត្រាពន្ធនៃប្រទេសដែលទទួលបានការអនុគ្រោះបំផុត(MFN) ប៉ុន្តែការទាមទារឲ្យមានប្រព្រឹត្តកម្មអនុគ្រោះពន្ធទូទៅ(GSP)គួរបន្តធ្វើឡើងពីព្រោះការអនុវត្តនាពេលកន្លងមករបស់សភាអាមេរិកដែលបានបន្តកម្មវិធីនេះគឺមានលក្ខណៈប្រតិសកម្មចាប់ពីកាលបរិច្ឆេទផុតរលត់ពិតប្រាកដ ធ្វើដូច្នេះ អ្នកនាំចូលនឹងទទួលបានប្រាក់ពន្ធដែលបានបង់ត្រឡប់ទៅវិញ(មិនមានការប្រាក់)សម្រាប់ពន្ធដែលបានបង់ក្នុងអំឡុងរយៈពេលផុតរលត់។

សូមមើលតំណភ្ជាប់ខាងក្រោមនេះសម្រាប់ឯកសារយោងជាផ្លូវការ។

https://content.govdelivery.com/bulletins/gd/USDHSCBP-2b25e93?wgt_ref=USDHSCBP_WIDGET_2?utm_source=help.cbp.gov&utm_medium=help.cbp.gov&utm_term=undefined&utm_content=undefined&utm_campaign=(not%20set)&gclid=undefined&dclid=undefined&GAID=668218302.1609171616

សមាគមសង្ឃឹមថា ការផ្ដល់កម្មវិធីនេះឡើងវិញដោយសភាអាមេរិកនឹងកើតឡើងនាពេលខាងមុខឆាប់ៗ ហើយសមាគមនឹងជម្រាបសមាជិកទាំងអស់ភ្លាមៗនៅពេលទទួលបានព័ត៌មាន។

ភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

GARMENT MANUFACTURERS ASSOCIATION IN CAMBODIA

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា Garment Manufacturers Association in Cambodia សមាគមរោងចក្រកាត់ដេរនៅកម្ពុជា Garment Manufacturers Association in Cambodia

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantouk, Khan Por Sen Chey, Phnom Penh, Cambodia.
Tel: (855) 23-301 181 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org